# គោលការណ៍គណនេយ្យភាព ឬការទទួលខុសត្រូវខ្ពស់
# នៃគំរោងកម្មវិធីទទួលខុសត្រូវខ្ពស់ផ្នែកជំនួយមនុស្សធម៌អន្តរជាតិ

## Humanitarian Accountability Principle of Humanitarian Accountability Partnership International

### ១. ប្ដេជ្ញាចិត្តគោរពបទដ្ឋានមនុស្សធម៌ និង សិទ្ធិ

- អង្គការជាសមាជិកទាំងអស់ត្រូវបញ្ជាក់នូវការប្ដេជ្ញាចិត្តរបស់ខ្លួនដោយគោរព និង ផ្ដត់ផ្ដង់ជំនួយមនុស្សធម៌តំរូវតាមបទដ្ឋាន និង សិទ្ធិរបស់អ្នកទទួលផល ឬ អ្នករងគ្រោះ។

### ២. ការកំណត់បទដ្ឋាន និង ការកសាងសមត្ថភាព

- អង្គការជាសមាជិកទាំងអស់ត្រូវបង្កើតគំរោងនៃការទទួលខុសត្រូវខ្ពស់ដល់គ្រប់ភាគីពាក់ពន្ធ័។
- អង្គការជាសមាជិកទាំងអស់ត្រូវបង្កើត និង ពិនិត្យឡើងវិញតាមពេលកំណត់នូវបទដ្ឋាន នឹងកត្តាចង្អុលបង្ហាញស្នាដៃការងារនានារបស់ខ្លួន និង ធ្វើការកែតំរូវឡើងវិញបើចាំបាច់។
- អង្គការជាសមាជិកទាំងអស់ត្រូវផ្ដល់នូវវគ្គបណ្ដុះបណ្ដាលសមរម្យដើម្បីប្រើប្រាស់ និង អនុវត្តន៏បទដ្ឋានទាំងនោះ។

### ៣. ទំនាក់ទំនង

- អង្គការជាសមាជិកទាំងអស់ត្រូវផ្ដល់ពត៏មាន និង ធ្វើការពិគ្រោះយោបល់ជាមួយគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសជាមួយ អ្នកទទួលផលឬអ្នករងគ្រោះ និង បុគ្គលិកអំពីបទដ្ឋាននានា

  ដែលបានបង្កើតឡើងអំពីកម្មវិធីដែលត្រូវធ្វើ និង យន្តការសំរាប់ដោះស្រាយការព្រួយបារម្ភ ការប្ដឹងតវ៉ាផ្សេងៗ។

### ៤. ការចូលរួមជាមួយកម្មវិធី

- អង្គការជាសមាជិកទាំងអស់ត្រូវអនុញ្ញាតអោយអ្នករងគ្រោះចូលរួមក្នុងការកសាងផែនការការអនុវត្តន៏ ការត្រួតពិនិត្យ និងការវាយតំលៃទៅលើគំរោងកម្មវិធី និង រាយការណ៏អោយពួកគេទាំងអស់គ្នាបានដឹងអំពីដំណើរការ និងភាពរីកចំរើនរបស់គំរោងវាលើកលែងតែក្នុងករណីដែលមានឧបសគ្គធ្ងន់ធ្ងរបំផុតដែលមិនអាចធ្វើទៅបាន។

### ៥. ការត្រួតពិនិត្យ និង រាយការណ៍អំពីសកម្មភាព ដែលបានព្រមព្រៀងគ្នា នៅក្នុងផែនការ និង ការអនុវត្តន៏

- អង្គការជាសមាជិកទាំងអស់ត្រូវអនុញ្ញាតអោយបុគ្គលិករបស់ខ្លួន និង អ្នករងគ្រោះចូលរួមតាមដានត្រួតពិនិត្យ និងមានការចូលរួមក្នុងការកែតំរូវនូវបទដ្ឋាននានា។
- អង្គការជាសមាជិកទាំងអស់ធ្វើការត្រួតពិនិត្យតាមដាន និង វាយតំលៃយ៉ាងទៀងទាត់អំពីការអ្វីដែលបានឯកភាព ឬ បានព្រមព្រៀងគ្នានៅក្នុងគំរោងការអនុវត្តន៏ជាមួយនិង បទដ្ឋាននានាក្នុងដំណើរការមួយយ៉ាងសកម្មបំផុត។
- អង្គការជាសមាជិកទាំងអស់ត្រូវធ្វើរបាយការណ៍យ៉ាងតិចមួយឆ្នាំម្ដងដល់ភាគីពាក់ពន្ធ័រួមទាំងអ្នកទទួលផល អំពីសកម្មភាពដែលបានព្រមព្រៀងគ្នានៅក្នុងគំរោង។
- របាយការណ៏អាចធ្វើឡើងក្នុងទំរងទំរង់បែបបទផ្សេងៗគ្នា។

### ៦. ការដោះស្រាយបណ្ដឹងតវ៉ាផ្សេងៗ

- អង្គការជាសមាជិកទាំងអស់ត្រូវផ្ដល់ឱកាសនិងអនុញ្ញាតអោយអ្នកទទួលផលនិងបុគ្គលិករបស់ខ្លួនបានរាយការណ៏អំពីការមិនសុខចិត្ត ឬ បណ្ដឹងតវ៉ាផ្សេងៗនិងព្យាយាមដោះស្រាយដោយ

  សន្តិវិធី។

### ៧. ការអនុវត្តន៍របស់ដៃគូ

- នៅពេលធ្វើការតាមរយៈអង្គការជាដៃគូរបស់ខ្លួនអង្គការជាសមាជិកទាំងអស់ត្រូវប្ដេជាចិត្តធ្វើយ៉ាងណាអោយអង្គការជាដៃគូប្រកាន់ខ្ជាប់ និង អនុវត្តន៏នូវគោលការណ៏ទាំងនេះ។

**HANet CAMBODIA**
Humanitarian Accountability Network in Cambodia